ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថាប័នប្រឆាំងអំពើពុករលួយ
**អង្គភាពប្រឆាំងអំពើពុករលួយ**
លេខ ០៤៦/សរ ..... អ.ប.ព.
២៦

# សេចក្តីសម្រេច
# ស្តីពី
# ការទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តមណ្ឌលគិរី

## ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/00៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- យោងសេចក្តីសម្រេចលេខ ០២៩/២៦ ស.រ អ.ប.ព. ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការបង្កើតក្រុមការងារដឹកនាំការងារសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦
- យោងសេចក្តីជូនដំណឹងលេខ 00៤/២៦ ស.ជ.ណ អ.ប.ព. ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ស្តីពីការជ្រើសរើសអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ដែលបានកំណត់អំពីចំនួនអ្នកសង្កេតការណ៍ស្ម័គ្រចិត្តរបស់ អ.ប.ព. នៅតាមរាជធានី-ខេត្តនីមួយៗ អំពីលក្ខខណ្ឌចុះឈ្មោះជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត (មានអាយុចាប់ពី ២១ ឆ្នាំឡើងទៅ - និស្សិត ឬបុគ្គលផ្សេងទៀតក្រៅពីព្រះសង្ឃ (កំពុងគង់ចាំព្រះវស្សា) គ្រូបង្រៀន មន្ត្រីរាជការសាធារណៈ និងអ្នកសារព័ត៌មាន - មិនត្រូវចូលរួមសង្កេតការណ៍ក្នុងមណ្ឌលប្រឡងដែលមានបងប្អូន សាច់ញាតិ ឬមិត្តភ័ក្តិជាបេក្ខជនប្រឡងដែលនេះជាទំនាស់ផលប្រយោជន៍ - ត្រូវឬធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល/កិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការងារសង្កេតការណ៍ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ - ត្រូវទាញយកកម្មវិធី Angkor Life មកប្រើប្រាស់សម្រាប់ការជូនដំណឹង និងTelegram សម្រាប់ទំនាក់ទំនងការងារសង្កេតការណ៍ - មានមធ្យោបាយ ធនធាន ពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងារសង្កេតការណ៍ស្ម័គ្រចិត្តដោយខ្លួនឯង រួមទាំងមធ្យោបាយធ្វើដំណើរ - គោរពតាមច្បាប់ បទប្បញ្ញត្តិលិខិតបទដ្ឋានគតិយុត្តជាធរមាន ការចាត់តាំង ដឹកនាំ ប្រគល់ភារកិច្ចរបស់ក្រុមដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល ជាពិសេសគោរពបានយ៉ាងខ្ជាប់ខ្ជួនបទប្បញ្ញត្តិ សេចក្តីណែនាំ ស្តីពីតួនាទីភារកិច្ចអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត និងអំពីលក្ខខណ្ឌសម្រេចជ្រើសរើសបេក្ខជន - អាទិភាពជ្រើសរើសបេក្ខជនដាក់ពាក្យមុន - និស្សិតកំពុងសិក្សាតាមគ្រឹះស្ថានសិក្សានានា - មិនធ្លាប់ចូលរួមសង្កេតការណ៍ - អាទិភាពនារី - មានអាយុច្រើន)
- យោងតម្រូវការចាំបាច់នៃការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ

# សម្រេច

## ប្រការ ១._

**ខេត្តមណ្ឌលគិរី** មានអ្នកដាក់ពាក្យជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្តសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចំនួន ៣២នាក់ (អ្នកដាក់ពាក្យ)។ សម្រាប់ខេត្តមណ្ឌលគិរី អង្គភាពប្រឆាំងអំពើពុករលួយ (អ.ប.ព.) មានគម្រោងជ្រើសរើសអ្នកសង្កេតការណ៍ចំនួន ២៥នាក់ (ហៅថាអ្នកសង្កេតការណ៍)។

ក្នុងចំណោមអ្នកបានដាក់ពាក្យចំនួន ២៥នាក់ មុនគេបំផុត អ.ប.ព. បានពិនិត្យឃើញថា មានអ្នកដាក់ពាក្យចំនួន ១២នាក់ ដែលមិនបានបំពេញគ្រប់តាមលក្ខខណ្ឌ ហេតុដូចនេះ អ.ប.ព. ក៏បានបន្តពិនិត្យអ្នកបានដាក់ពាក្យទាំងអស់ ដោយទទួលបានអ្នកសង្កេតការណ៍គ្រប់លក្ខខណ្ឌចំនួន ១៩នាក់។

## ប្រការ ២._

ទទួលស្គាល់សមាសភាពអ្នកសង្កេតការណ៍សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ នៅខេត្តមណ្ឌលគិរីចំនួន ១៩នាក់។

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| ១. មណ្ឌលវិទ្យាល័យ ហ៊ុន សែន មណ្ឌលគិរី លិច | | | |
| 1 | 1 | លឹម សោភា | ស្រី |
| 2 | 2 | ឌី កញ្ញារ៉ា | ស្រី |
| 3 | 3 | ភោគ សេដ្ឋសន្តាលីន | ស្រី |
| ២. មណ្ឌលវិទ្យាល័យ ហ៊ុន សែន មណ្ឌលគិរី កើត | | | |
| 4 | 1 | ផល្លា វីដា | ស្រី |
| 5 | 2 | ពែក ស្រីលាក | ស្រី |
| 6 | 3 | ក្វៃ តាញ់ | ប្រុស |
| 7 | 4 | សម្បត្តិ រតនា | ស្រី |
| 8 | 5 | យិន សុប៉ោម | ស្រី |
| 9 | 6 | ជុំជា ចរិយា | ស្រី |
| 10 | 7 | ស៊ឹម ច័ន្ទដារី | ស្រី |

| ល.រ. | | គោត្តនាម-នាម | ភេទ |
|---|---|---|---|
| 11 | 8 | ញ៉ាវ៉ាងចាន់ សុវណ្ណនិស្ស័យ | ស្រី |
| 12 | 9 | ញឹប កុម្ភៈ | ប្រុស |
| 13 | 10 | ឈិន ចាន់ថុល | ប្រុស |
| 14 | 11 | ពែក សុខ | ប្រុស |
| 15 | 12 | រ័ត្ន ដារីន | ស្រី |
| 16 | 13 | គង់ ប៉ូច | ប្រុស |
| 17 | 14 | វ៉ាន់ ស្រីម៉ៅ | ស្រី |
| 18 | 15 | ឡាញ ស្រីនាង | ស្រី |
| 19 | 16 | រី លីតា | ស្រី |

## ប្រការ ៣._

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តស្ថិតក្រោមការចាត់តាំង ដឹកនាំ និងប្រគល់ភារកិច្ចរបស់ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល។

អ្នកសង្កេតការណ៍ស្ម័គ្រចិត្តត្រូវបំពេញភារកិច្ចឱ្យបានខ្ជាប់ខ្ជួនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានជាអាទិ៍ឧបសម្ព័ន្ធ២ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ កាតព្វកិច្ច និងវិន័យ សម្រាប់អ្នកសង្កេតការណ៍ស្ម័គ្រចិត្តនៃសេចក្តីណែនាំ ស្តីពីការងារសង្កេតការណ៍របស់អង្គភាពប្រឆាំងអំពើពុករលួយលើដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ១០ សីហា ២០២៦ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦។

## ប្រការ ៤._

ក្រុមការងារដឹកនាំសង្កេតការណ៍ថ្នាក់កណ្តាល ថ្នាក់រាជធានី-ខេត្ត និងថ្នាក់មណ្ឌល សាមីខ្លួនដូចមានក្នុងប្រការ ២ ខាងលើ និងផ្នែកពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២៦

ទេសរដ្ឋមន្ត្រី

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

កិត្តិនីតិកោសលបណ្ឌិត ឱម យ៉ិនទៀង

<u>កន្លែងទទួល៖</u>
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ